# មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍

## COMMUNITY LEGAL EDUCATION CENTER

## វគ្គបណ្តុះបណ្តាលពិសេសរយៈពេល ៤ថ្ងៃ ស្តីពីច្បាប់ការងារ

ថ្ងៃទី ៣០-៣១ ខែ មីនា ដល់ ថ្ងៃទី ០១-០២ ខែ មេសា ២០១០

(កាលបរិច្ឆេទនៃការចុះឈ្មោះ នឹងត្រូវបញ្ចប់ត្រឹមថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០១០)

មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍រៀបចំបើក វគ្គបណ្តុះបណ្តាល អំពីច្បាប់ស្តីពីការងារកម្ពុជា រយៈពេល ៤ថ្ងៃ ចាប់ពី ថ្ងៃទី ៣០-៣១ ខែ មីនា ដល់ ថ្ងៃទី ០១-០២ ខែ មេសា ២០១០ ពេលព្រឹក ពីម៉ោង ០៨:០០ ដល់ម៉ោង ១២:០០ និងពេលរសៀលពីម៉ោង ១៣:៣០ ដល់ម៉ោង ១៧:០០។ វគ្គបណ្តុះបណ្តាលនេះ ធ្វើឡើងជាភាសាខ្មែរ។

អ្នកដែលធ្វើការនៅផ្នែករដ្ឋបាល ធនធានមនុស្ស និងផ្នែកគោលនយោបាយរបស់ស្ថាប័ន ត្រូវបានលើកទឹកចិត្តសំរាប់ការចុះឈ្មោះក្នុងវគ្គបណ្តុះបណ្តាលនេះ ។

វគ្គបណ្តុះបណ្តាលនេះ ផ្តោតទៅលើទំនាក់ទំនងតាមផ្លូវច្បាប់រវាងនិយោជក និង កម្មករនិយោជិត យោងទៅតាមច្បាប់ស្តីពីការងារកម្ពុជា ។

ប្រធានបទសំខាន់ដូចខាងក្រោម នឹងត្រូវលើកយកមកពិភាក្សានៅក្នុងវគ្គបណ្តុះបណ្តាលនេះមាន :

- តើកម្មករនិយោជិត និង និយោជកណាខ្លះ ស្ថិតនៅក្រោមច្បាប់ការងារ
- សិទ្ធិ និង កាតព្វកិច្ចរបស់កម្មករនិយោជិត និង និយោជកតាមច្បាប់ការងារ
- កិច្ចសន្យាការងារ
- លក្ខខណ្ឌការងារ( ប្រាក់ឈ្នួល ថិរវេលាធ្វើការ ការឈប់សំម្រាក ...)
- នីតិវិធីនៃការដោះស្រាយវិវាទការងារ
- របបសន្តិសុខសង្គម
- សេរីភាពសមាគម
- អនុសញ្ញារួម

វិភាគទានសិក្សា ៤០ដុល្លារសហរដ្ឋអាមេរិក សម្រាប់អ្នកចូលរួមម្នាក់ដែលបង់ដោយស្ថាប័ន ឬ ២០ដុល្លារសហរដ្ឋអាមេរិក សម្រាប់អ្នកបង់ថ្លៃដោយខ្លួនឯង ។ មានចែកជូនសៀវភៅច្បាប់ស្តីពីមុខរបរ និងការងារកម្ពុជា និងឯកសារផ្សេងៗ ដោយឥតគិតថ្លៃ ។

**ការចុះឈ្មោះ :** សូមទាក់ទងមក មជ្ឈមណ្ឌអប់រំច្បាប់សម្រាប់សហគមន៍ តាមទូរស័ព្ទលេខ ០២៣ ២១១ ៧២៣ e-mail: admin@clec.org.kh ឬទីស្នាក់ការលេខ ៥៤ ផ្លូវលេខ ៣០៦ សង្កាត់បឹងកេងកងទី១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។ កន្លែងមានកំណត់ត្រឹមតែ៣០នាក់ប៉ុណ្ណោះ ។